

# ចុះឈ្មោះបោះឆ្នោត និង ចូលរួមបោះឆ្នោត

**សេរីការ**

ចុះឈ្មោះបោះឆ្នោត ជា ករណីយកិច្ច របស់ជនខ្មែរម្នាក់ៗ ដើម្បីបំពេញលក្ខណៈខ្លួន ជា ពលរដ្ឋ មានការទទួលខុសត្រូវ លើជោគវាសនាជាតិ ម្លោះហើយ ត្រូវនាំគ្នាទៅចុះឈ្មោះ នៅក្នុងបញ្ជីបោះឆ្នោត។ អត្ថៈពិសេស (signification particulière) មួយទៀតដែរ គឺការសំដែងទឹកចិត្ត នៃសេចក្តីស្រឡាញ់លទ្ធិប្រជាធិបតេយ្យ ព្រោះការបោះឆ្នោត ជា អត្ថរស់មួយ នៃលទ្ធិនេះ។ ទៅចុះឈ្មោះក្នុងបញ្ជីបោះឆ្នោត ជា ដំណាក់ការចាំបាច់ណាស់ សំរាប់ទទួលសិទ្ធិ ជាពលរដ្ឋ ដែលជាម្ចាស់អំណាច ក្នុងការជ្រើសរើសតាមការបោះឆ្នោតរើសតំណាងប្រជាពលរដ្ឋ សំរាប់ដឹកនាំកិច្ចការជាតិ ក្នុងនាមប្រជាពលរដ្ឋ ដើម្បីប្រជាពលរដ្ឋ។ ពិតមែនហើយថា ការចុះឈ្មោះក្នុងបញ្ជីបោះឆ្នោត វាមិនមែន ជាកាតព្វកិច្ច ជាគតិយុត្ត តែវា ជា កាតព្វកិច្ច ជាសីលធម៌ ព្រោះបើសិនជនខ្មែរ មានចិត្តព្រងើយនឹងករណីយកិច្ចនេះ វាអាចជា គ្រោះថ្នាក់ ដល់ប្រជាជាតិ ដ្បិត វាអាចបើកដៃអោយពួកអ្នកភាគតិចសកម្ម (minorité agissante) ចាប់យកអំណាចដឹកនាំជាតិបាន ព្រោះពួកនេះគេសកម្មណាស់ ក្នុងជីវិតភាពនយោបាយ តួយ៉ាង ជនជាតិយួន ដែលមករស់នៅស្រុកខ្មែរមានសញ្ជាតិ ជា ខ្មែរ ត្រូវច្បាប់ក្តី ខុសច្បាប់ក្តី គេនាំគ្នា សម្រុកទៅចុះឈ្មោះបោះឆ្នោតដើម្បី ការពារប្រយោជន៍និគមជនគេ

ជា ពិសេស បើគេមានឈ្មោះក្នុងបញ្ជីបោះឆ្នោត គឺ គេក្លាយ ជា ពលរដ្ឋខ្មែរពេញលេញ ដូច្នេះ គេ ជា ម្ចាស់អំណាច នៅក្នុងស្រុកខ្មែរស្របតាមច្បាប់រដ្ឋធម្មនុញ្ញ។ ខ្មែរយើងដឹងច្បាស់ថា ជនជាតិយួនមានសញ្ជាតិ ជា ខ្មែរ ជា អតិថិជន នៃគណបក្សប្រជាជនកម្ពុជា ព្រោះជាអ្នកបោះឆ្នោត អោយតែគណបក្សនេះ មិនមែន ដើម្បី ការពារប្រជាយោជន៍ជាតិខ្មែរនោះឡើយ ព្រោះប្រយោជន៍ខ្មែ វាផ្ទុយគ្នាស្រឡះពី ប្រយោជន៍នៃប្រជាជាតិយួន ដែលមានប្រវត្តិសាស្រ្តខ្មែរ និង ការពិតនៃស្ថានភាពនៅស្រុកខ្មែរសព្វថ្ងៃ ជាភស្តុតាង។ តែអ្នកដែលបោះឆ្នោតអោយគណបក្សប្រជាជនកម្ពុជា ក្នុងឋានៈ ជា ពលរដ្ឋខ្មែរស្របច្បាប់ វាជាសេរីភាពរបស់ គេដែលខ្មែរសព្វគ្នាត្រូវគោរព ព្រោះជា សេរីភាពស្របច្បាប់។ ដូច្នេះបញ្ហា នៃការបោះឆ្នោត វាមិនឋិតនៅលើសេរីភាព របស់ពលរដ្ឋខ្មែរម្នាក់ៗ ក្នុងការជ្រើសរើសគណបក្សណាមួយ ដែលខ្លួនជ្រើសយក ជា តំណាង នៃគោល សន្ទុវត្តគំនិត (idée intime) របស់ខ្លួននោះឡើយ បញ្ហា ដែលមាន វានៅលើ ការប្រគល់សញ្ជាតិខ្មែរឲជនបរទេស ដែលរស់នៅក្នុងស្រុកខ្មែរ ថាតើ ការប្រគល់នេះ វាស្របនឹងច្បាប់ នៃសញ្ជាតិខ្មែរដែរឬទេ ? បើវាស្របនឹងច្បាប់ គឺវាច្បាស់ជាគ្មានបញ្ហានោះឡើយ តែបើវាផ្ទុយនឹងច្បាប់វិញ អ្នកដែលប្រឆាំងនឹងសិទ្ធិ អោយជនបរទេស មានសញ្ជាតិខ្មែរខុសច្បាប់ ចុះឈ្មោះ ក្នុងបញ្ជីបោះឆ្នោត វាជាបដិយោគ ជាធម្មានុរូប (opposition légitime) ព្រោះ វាជាករណីកិច្ច របស់ពលរដ្ឋខ្មែរម្នាក់ៗ ដែល ជា ម្ចាស់អំណាច ប្រើសិទ្ធិ ដើម្បីការពារប្រយោជន៍ជាតិ។ បើនៅប្រទេស មាននីតិ

រដ្ឋ ពលរដ្ឋម្នាក់ៗ ឬ រួមគ្នា ជា សមូហជន អាចប្តឹងផ្ទាល់ទៅអាជ្ញាធរពាក់ព័ន្ធ ឬ ជូនដំណឹងទៅរដ្ឋសភា តាមរយៈតំណាងរាស្ត្រ អោយពិនិត្យ ជាចាំបាច់ នូវករណីនេះ តែដោយសារនៅស្រុកខ្មែរ ជា ប្រទេសគ្មាននីតិរដ្ឋ បញ្ហាគតិយុត្តនេះ វាក្លាយទៅជា វិបត្តិ នៃវិស្សសភាព (crise de confiance) ទៅលើអ្នកដឹកនាំ និងគ្រប់ស្ថាប័នជាតិ ជា ពិសេស ទៅលើប្រព័ន្ធយុត្តិធម៌។ ការមានវិបត្តិ នៃវិស្សសភាពនេះឯងហើយ ដែលនាំអោយខ្មែរយើងមួយភាគអស់មានជំនឿ ទៅលើការបោះឆ្នោតតែម្តង ព្រោះទុកវាគ្រាន់តែ ជា មធ្យោបាយខុសកន្លងធម៌ សំរាប់គណបក្សកាន់អំណាច នៅក្រោមអាជ្ញាធរអណានិគមយួន រក្សាអំណាចផ្តាច់ការរបស់ខ្លួនតែប៉ុណ្ណោះ។ បើយើងលើកយកករណី គ.ជ.ប. សព្វថ្ងៃ ដែលជា អង្គការ ដែលគណបក្សប្រឆាំង គេទុកជាស្នាដៃអភិសម័យ (œuvre réussite) របស់គេ យើងឃើញថា វាគ្មានសុពលភាពត្រឹមត្រូវ សំរាប់ធ្វើកិច្ចការរបស់ខ្លួនផង ព្រោះសមាជិករបស់ខ្លួនម្នាក់ កំពុងនៅក្នុងពន្ធនាគារ ដែលនាំអោយ គោលវិធី នៃការសំរេចយកមតិភាគច្រើនជាបានការ បាត់នូវសមតា ដូច្នេះ ដំណើរការ នៃគ.ជ.ប. សព្វថ្ងៃ វាអាចចាត់ទុកវា ថាខុសច្បាប់ផងដែរ តែករណីនេះ គណបក្សប្រឆាំង គាត់ធ្វើមិនដឹងឮទេ។

គួរខ្មែរយើងចែកអោយដាច់ អំពី ករណីយកិច្ច របស់ខ្មែរម្នាក់ទៅចុះឈ្មោះក្នុងបញ្ជីបោះឆ្នោត ពី ការចូលរួមបោះឆ្នោត។ ទី១ ត្រូវតែធ្វើជាការចាំបាច់ ព្រោះវាជាករណីយកិច្ចរបស់ពលរដ្ឋ តែ

ចំពោះករណីទី២ ត្រូវនាំគ្នាគិតពិចារណាអោយបានច្បាស់លាស់ ព្រោះវាអាចនឹងមានកម្មវិបាក បើសិននាំគ្នា ចូលរួមបោះឆ្នោត ក្នុងការបោះឆ្នោតមួយ ឥតសេរី និងឥតយុត្តិធម៌ ព្រោះគ្រប់បញ្ហា វានឹងមានកើតឡើងដូចគ្នានឹងការបោះឆ្នោត នៅឆ្នាំ ២០១៣ គឺថា គណបក្សកាន់អំណាច គេមិនគោរពឆន្ទៈរបស់ម្ចាស់ឆ្នោតជា ដាច់ខាតព្រោះថា គេមានម្ចាស់រួចហើយ គឺអ្នកដឹកនាំយួនកុម្មុនិស្ត ដែលជា ម្ចាស់អំណាច នៅស្រុកខ្មែរ។ ពួកអ្នកដឹកនាំយួន គេយកការបោះឆ្នោត សំរាប់តែបំភាន់សហគមអន្តរជាតិថា អំណាចនៅស្រុកខ្មែរ ជា អំណាចធិបតេយ្យ ដូច្នេះមិនអាចបរទេសណា អាចជ្រៀតជ្រែកចូល នៅក្នុងកិច្ចការផ្ទៃក្នុង របស់កម្ពុជាបាននោះឡើយ។ រួមសេចក្តីមក គឺថា បើស្រុកខ្មែរ ស្ថិតនៅក្រោមឥទ្ធិពលយួនកុម្មុនិស្ត វាមិនអាចនឹងមានការបោះឆ្នោត ជាសេរី និងប្រកបដោយយុត្តិធម៌បាននោះឡើយ ម្លោះហើយ គ្រប់គណបក្សនយោបាយ ដែលយកការបោះឆ្នោត ជាមធ្យោបាយ សំរាប់ប្តូរអ្នកដឹកនាំគឺគ្រាន់តែជាមាយាការ (illusion) ហើយ យកសេចក្តីភាន់នេះទៅបញ្ឆោតប្រជាពលរដ្ឋថាវាជាសេចក្តីពិត។

អ្វីដែលយើងលើកយកមក បង្ហាញនៅទីនេះ វាមិនមែន ជាឱវាទ តែគ្រាន់តែជាការណ៍សួរជាសំណួរមួយចំនួន(questionnement) ដល់អ្នកនយោបាយ និងប្រជាពលរដ្ឋខ្មែរ ថាតើ នរណាជា អ្នករងគ្រោះរហូតមកដល់សព្វថ្ងៃនេះ ? បើនាំគ្នាឆ្លើយថា ប្រជាពលរដ្ឋខ្មែរ ជា អ្នករងគ្រោះ ដូច្នេះយើងអាចសួរ ជា សំណួរមួយ

ទៀតថា ការបោះឆ្នោត នៅក្នុងរបបបច្ចុប្បន្ន ដែលខ្មែរភាគច្រើន ទុកជា តិរច្ឆាន តើវាពិត ជា ដំណោះស្រាយអាក្រក់តិចជាងគេនោះដែរឬទេ សំរាប់ប្រជាជាតិខ្មែរ ? ចម្លើយ គឺវាមាននៅក្នុងសតិសម្បជញ្ញៈរបស់ខ្មែរម្នាក់ៗនៅពេលបោះឆ្នោត។ បើខ្មែរយើង មើលឃើញថា ការបោះឆ្នោត វាគ្រាន់តែជាការបញ្ឆោត របស់យួនកុម្មុយនិស្ត ពួកអ្នកជាប់ឃ្នាង និងពួកអ្នកនយោបាយជាប់នៅក្នុងទ្រុងយួន ហើយនៅតែនាំគ្នាចូលរួមបោះឆ្នោត ដូច្នេះកិច្ចហ្នះ (cet acte) គឺជាការទទួលខុសត្រូវរបស់ខ្មែរទាំងពួង នៅចំពោះកម្មវិបាកបន្ទួន កើតមានឡើងពីរាល់ការបោះឆ្នោត នៅក្នុងយុទ្ធសាស្ត្រ របស់អ្នកដឹកនាំយួន សំរាប់លេបយកទឹកដីខ្មែរ។ កុំនាំគ្នានឹកស្មានថា ករណីខ្មែរ វាដូចគ្នានឹងប្រទេសភូមា ព្រោះប្រទេសភូមា មិនស្ថិតនៅក្រោមអំណាចបរទេសណាមួយឡើយ ដូច្នេះ គេអាចមាន ការផ្សះផ្សាជាតិ ដើម្បីប្រយោជន៍ របស់ប្រជាជាតិគេ រីឯនៅស្រុកខ្មែរ វិញអ្នកដឹកនាំយួន គេទុកការផ្សះផ្សាជាតិ រវៀងខ្មែរនឹងខ្មែរ ជាសត្រូវនឹងប្រយោជន៍គេ តែម្តង។ ត្រូវដឹងថា អាក្បកិរិយានយោបាយ (posture politique) របស់ គណបក្សសង្គ្រោះជាតិ « មិនយកខ្មែរណាជាសត្រូវ » ជា ឧត្តមគំនិតមួយល្អណាស់ តែនៅក្នុងបរិបទខ្មែរ គំនិតនេះ វាគ្រាន់តែជា គតិបណ្ឌិត ឬ ជាមធ្យោបាយវៀចវេរ ពីបញ្ហាពិត (biais du problème réel) ដែលនាំឲអ្នកដឹកនាំគណបក្សសង្គ្រោះជាតិនិងគណបក្សដទៃទៀតមើលឃើញតែ ការបោះឆ្នោត ក្នុងលក្ខណៈយ៉ាងណាក្តី ជា ដំណោះស្រាយតែមួយគត់ សំរាប់សង្គ្រោះប្រជាជាតិខ្មែរ។ អនាគតកាល

នឹងថ្លែងទុក្ខម្តងទៀត ពីជំនឿស៊ប់លើ ការបោះឆ្នោតនេះ។ ដូច្នេះ ការចុះឈ្មោះនៅក្នុងបញ្ជីបោះឆ្នោត មិនមានន័យថាត្រូវតែចូលរួមបោះឆ្នោត នៅក្នុងយុទ្ធសាស្រ្តយួនកុម្មុយនិស្តនោះឡើយ។